វគ្គបណ្តុះបណ្តាលជំនួយក្នុងការផ្សព្វផ្សាយអំពីក្រមរដ្ឋប្បវេណី - ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា លើកទី៤

# ស្តីពីអង្គហេតុចំបងដែលជាធាតុផ្សំ (1)

## —ការទាមទារឱ្យបង់ថ្លៃលក់ទិញ—

ថ្ងៃទី12 ខែមិថុនា ឆ្នាំ2014

មេធាវី Hiroshi Hasegawa

1

# I ការទាមទាររបស់ដើមចោទ X

2

## 1　រឿងក្តី (ការអះអាងរបស់ដើមចោទX)

### ការអះអាងរបស់ X

នៅថ្ងៃទី៣ មីនា ២០១៤ ខ្ញុំបានលក់ចូបុរាណ P មួយក្នុងតម្លៃ១ម៉ឺនដុល្លារទៅឱ្យ Y។

ក៏ប៉ុន្តែ Y បានយកលេសនេះ លេសនោះ មិនព្រមបង់ថ្លៃទិញនោះទេ។ ហេតុនេះហើយ ខ្ញុំក៏ទាមទារឱ្យគាត់បង់ថ្លៃ១ម៉ឺនដុល្លារនេះ។

3

## 2　គោលគំនិតនៃការទាមទារ

### គោលគំនិតនៃការទាមទារ គឺ

គឺជាផ្នែកសន្និដ្ឋានក្នុងការអះអាងរបស់ដើមចោទនៅក្នុងបណ្តឹង (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ខ. “សាលក្រមដែលទាមទារ”)

ចុងចម្លើយត្រូវបង់ប្រាក់១ម៉ឺនដុល្លារ ចំពោះដើមចោទ។

4

# 3　កម្មវត្ថុនៃបណ្តឹង

កម្មវត្ថុនៃបណ្តឹងគឺ

សិទ្ធិ ឬទំនាក់ទំនងគតិយុត្តកំណត់មួយ ដែលជាខ្លឹមសារនៃការទាមទារតាមផ្លូវបណ្តឹង (ការអះអាងរបស់ដើមចោទ)

សិទ្ធិទាមទារឱ្យបង់ថ្លៃលក់ទិញ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ　　សិទ្ធិមួយ

5

# ៣ដំណាក់កាល គឺ ការទាមទារ ការអះអាង ការបញ្ជាក់ភស្តុតាង (1)




6

## 4　មូលហេតុនៃការទាមទារ

### (1) អង្គហេតុចំបងដែលជាធាតុផ្សំនៃការទាមទារឱ្យបង់ថ្លៃលក់ទិញ

តើក្រមរដ្ឋប្បវេណី មាត្រា 515 ទាមទារអ្វីខ្លះ ដែលជាល័ក្ខខ័ណ្ឌដើម្បីបង្កើតកិច្ចសន្យាលក់ទិញ ?

ក្រមរដ្ឋប្បវេណី មាត្រា515 (និយមន័យនៃការលក់ទិញ)

ការលក់ទិញសំដៅទៅលើកិច្ចសន្យាមួយដែល
①ភាគីម្ខាងហៅថា អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិ ឱ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញ
②ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឱ្យអ្នកលក់ ។



## 4　មូលហេតុនៃការទាមទារ

### (2) តើអ្វីទៅ អង្គហេតុដែលត្រូវអះអាងជាអង្គហេតុចំបងដែលជាធាតុផ្សំ ?

### a　វត្ថុដែលជាកម្មវត្ថុ និង ថ្លៃជាប្រាក់

- យោងតាមក្រមរដ្ឋប្បវេណី មាត្រា515
  ត្រូវមានការព្រមព្រៀងស្តីពី
  ①ការផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ (វត្ថុដែលជាកម្មវត្ថុ) និង
  ②ការបង់ថ្លៃជាប្រាក់

- ដើម្បីឱ្យអាចថា មានការព្រមព្រៀង ចាំបាច់ត្រូវកំណត់ជាស្ថាពរនូវ
  ①វត្ថុដែលជាកម្មវត្ថុ　និង
  ②ថ្លៃជាប្រាក់ (វិធីកំណត់ថ្លៃជាប្រាក់)

# 4 មូលហេតុនៃការទាមទារ

## (2) តើអ្វីទៅ អង្គហេតុដែលត្រូវអះអាងជាអង្គហេតុចំបងដែលជាធាតុផ្សំ ?

### b កាលកំណត់ដែលត្រូវអនុវត្តកាតព្វកិច្ចបង់ថ្លៃជាប្រាក់

- តាមធម្មតា បើសិន័ជាពុំមានការព្រមព្រៀងអំពីកាលកំណត់បង់ទេ ត្រូវអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាព្រមគ្នាភ្លាម
- នៅក្នុងមូលហេតុនៃការទាមទារ X មិនចាំបាច់អះអាងអំពីការព្រមព្រៀងស្តីពីកាលកំណត់បង់ និងអះអាងថាកាលកំណត់បង់បានមកដល់ទេ
  - ការព្រមព្រៀងអំពីកាលកំណត់បង់→ការតវ៉ា (Yត្រូវអះអាងនិងបញ្ជាក់ភស្តុតាង)
  - កាលកំណត់បង់បានមកដល់→ការតវ៉ាតប (Xត្រូវអះអាងនិងបញ្ជាក់ភស្តុតាង)



# 4 មូលហេតុនៃការទាមទារ

## (2) តើអ្វីទៅ អង្គហេតុដែលត្រូវអះអាងជាអង្គហេតុចំបងដែលជាធាតុផ្សំ ?

### c កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុរបស់អ្នកលក់

- នៅក្នុងក្រមរដ្ឋប្បវេណី មាត្រា515 ពុំមានចែងអំពីម្ចាស់កម្មសិទ្ធិនៃវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញទេ ដូច្នេះ កិច្ចសន្យាលក់ទិញស្តីពីវត្ថុរបស់អ្នកដទៃ ក៏អាចបង្កើតបានដែរ (ក្រមរដ្ឋប្បវេណី មាត្រា531 កថាខ័ណ្ឌទី2)
- បញ្ហា “តើ X មានកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ ឬទេ” មិនមែនជាល័ក្ខខ័ណ្ឌដើម្បីបង្កើតកិច្ចសន្យាលក់ទិញទេ
  - “តើXធ្វើយ៉ាងណាដើម្បីក្លាយជាម្ចាស់កម្មសិទ្ធិលើថូ” (ឧទាហរណ៍ បានធ្វើលទ្ធកម្មតាមរយៈសន្តតិកម្ម) មិនមែនជាអង្គហេតុចំបងដែលជាធាតុផ្សំទេ

# 4 មូលហេតុនៃការទាមទារ

## (2) តើអ្វីទៅ អង្គហេតុដែលត្រូវអះអាងជាអង្គហេតុចំបងដែលជាធាតុផ្សំ ?

### d ការប្រគល់ថ្វ

- “ការប្រគល់ថ្វ” មិនមែនជាអង្គហេតុចំបងដែលជាធាតុផ្សំនៃការបង្កើតកិច្ចសន្យាលក់ទិញទេ
  - ក្នុងករណីដែល Yបានអះអាងតវ៉ាអំពីការអនុវត្តព្រមគ្នាថា “មិនអាចបង់ថ្លៃជាប្រាក់បានទេ មុនពេលដើមចោទប្រគល់ថ្វ” (ក្រមរដ្ឋប្បវេណី មាត្រា558 កថាខ័ណ្ឌទី1),
  - ពេលនោះ Xនឹងធ្វើការអះអាងតវ៉ាតបថា “បានប្រគល់វត្ថុដែលជាកម្មវត្ថុ (ថ្វ) ហើយ”



# 4 មូលហេតុនៃការទាមទារ

## (2) តើអ្វីទៅ អង្គហេតុដែលត្រូវអះអាងជាអង្គហេតុចំបងដែលជាធាតុផ្សំ ?

### e ការមិនបង់ថ្លៃ

- ពេលដែលបានបង្កើតកិច្ចសន្យាលក់ទិញហើយភ្លាមអ្នកលក់អាចទាមទារឱ្យបង់ថ្លៃភ្លាមៗបាន
- ការមិនទាន់បានបង់ថ្លៃ មិនមែនជាល័ក្ខខ័ណ្ឌដើម្បីទាមទារថ្លៃជាប្រាក់ទេ

# 4　មូលហេតុនៃការទាមទារ

## (3)ករណីនៃអង្គសេចក្តីនេះ (ការអះអាងរបស់X)

ជាលទ្ធផល

- ដូច្នេះ X គ្រាន់តែអះអាងនិងបញ្ជាក់ភស្តុតាងអំពី “a វត្ថុដែលជាកម្មវត្ថុ និង ទឹកប្រាក់នៃថ្លៃលក់ទិញ” បានហើយ

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៤ ដើមចោទបានលក់ថូ P ក្នុងតម្លៃ១ម៉ឺនដុល្លារ។

13

# II　ការឆ្លើយតបរបស់ចុងចម្លើយ Y

14

## 1 ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ(1)

### (1) របៀបធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់

① ការសារភាព（CCPមាត្រា123 កថាខ័ណ្ឌទី2）
② ការមិនទទួលស្គាល់
③ មិនដឹង（CCPមាត្រា96 កថាខ័ណ្ឌទី2）
④ នៅស្ងៀម（CCPមាត្រា96 កថាខ័ណ្ឌទី1）

### (2) ភាពចាំបាច់នៃការទទួលស្គាល់ ឬមិនទទួលស្គាល់

- អង្គហេតុចំបងដែលជាធាតុផ្សំ ដែលត្រូវបានសារភាព ត្រូវយកមកធ្វើជាមូលដ្ឋាននៃសាលក្រមតែម្តង (CCPមាត្រា123 កថាខ័ណ្ឌទី2)
- អង្គហេតុចំបងដែលជាធាតុផ្សំ ដែលត្រូវបានបដិសេធ ឬ មិនដឹង ត្រូវបញ្ជាក់អំពីអត្ថិភាពនោះ តាមរយៈការពិនិត្យភស្តុតាង (CCPមាត្រា123 កថាខ័ណ្ឌទី1)
- មានការចាំបាច់សម្រាប់រៀបចំចំណុចវិវាទ (តើអង្គហេតុណាខ្លះដែលត្រូវធ្វើការពិនិត្យភស្តុតាង?) និងជំនុំជម្រះព្រមទាំងវិនិច្ឆ័យឱ្យមានប្រសិទ្ធភាព

15

## ៣ដំណាក់កាល គឺ ការទាមទារ ការអះអាង ការបញ្ជាក់ភស្តុតាង (2)




16

## 1 ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ(2)

### (3) ការមិនទទួលស្គាល់ និង ការតវ៉ា

- បើសិនជាបានអះអាងថា មិនទទួលស្គាល់នូវមូលហេតុនៃការទាមទារ គឺជាការមិនទទួលស្គាល់

  ex. មិនមែនទិញទេ  គឺជាប្រទានកម្ម

  ex. មិនដែលខ្ចីទេ

- ទោះជាមានការទទួលស្គាល់នូវមូលហេតុនៃការទាមទារទាំងអស់ក៏ដោយ តែបើសិនជាមានការអះអាងដែលអាចបដិសេធនូវកំណើតសិទ្ធិ គឺជាការតវ៉ា

  ex. ខ្ញុំបានទិញមែន  តែត្រូវគេបោក ដូច្នេះ សូមលុបកិច្ចសន្យាវិញ (CCមាត្រា347 កថាខ័ណ្ឌទី1, មាត្រា348 កថាខ័ណ្ឌទី1)

  ex. បានខ្ចីដែរ តែបានសងហើយ

17

# 2 ការតវ៉ា

### (1) អត្ថន័យនៃការតវ៉ា

គឺជាការអះអាងដែលអាចបដិសេធនូវកំណើតនៃសិទ្ធិ ទោះជាបានទទួលស្គាល់នូវមូលហេតុនៃការទាមទារទាំងអស់ក៏ដោយ

### (2) ប្រភេទនៃការតវ៉ា

- ការតវ៉ាអំពីឧបស័គ

  （ឧ） ការលុបចោលដោយការភាន់ច្រឡំ (CC មាត្រា346 កថាខ័ណ្ឌទី1)

- ការតវ៉ាអំពីការរលាយ

  （ឧ） ការសង (CCមាត្រា433 ចំណុច ក.), អាជ្ញាយុកាលនៃការរលត់សិទ្ធិ (CC ពីមាត្រា480ទៅ)

- ការតវ៉ាអំពីការរាំង

  （ឧ） ការតវ៉ាឱ្យអនុវត្តព្រមគ្នា (CCមាត្រា551 កថាខ័ណ្ឌទី1)

18

# 2 ប្រភេទនៃការតវ៉ា

ចំណុចមួយនៅអតីតកាល　　　　បច្ចុប្បន្ន

a. កំណើត

b. ឧបស័គ

c. រលត់

d. រារាំង



19

# 3 ការតវ៉ាអំពីការភាន់ច្រឡំ

20

## 3 អង្គហេតុចំបងនៃការតវ៉ាស្តីពីការភាន់ច្រឡំ(1)

សូមពិចារណាអំពីអង្គហេតុចំបងដែលជាធាតុផ្សំ នៃ “ការតវ៉ាអំពីការភាន់ច្រឡំ” ដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណី

CCមាត្រា346 កថាខ័ណ្ឌទី1 (ការភាន់ច្រឡំ)

១-ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ ។

21

## 3 អង្គហេតុចំបងនៃការតវ៉ាស្តីពីការភាន់ច្រឡំ(2)

យោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី មាត្រា346កថាខ័ណ្ឌទី1

(1)ការបង្ហាញឆន្ទៈមានការភាន់ច្រឡំ

(2)ការភាន់ច្រឡំនេះពាក់ព័ន្ធនឹងចំណុច(កត្តា)សំខាន់នៃកិច្ចសន្យា

(3)ភាគីម្ខាងទៀតបានដឹងអំពី (1) និង (2)

22

## 3 អង្គហេតុចំបងនៃការតវ៉ាស្ដីពីការភាន់ច្រឡំ(3)

（ឯកសារយោង） នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន “ការដែលមានកំហុសធ្ងន់ធ្ងរនៃអ្នកភាន់ច្រឡំ” គឺជាការតវ៉ាតបចំពោះការតវ៉ាស្ដីពីការភាន់ច្រឡំ។

（ឯកសារ） ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា 95

បើសិនជាកត្តានៃសកម្មភាពគតិយុត្តមានការភាន់ច្រឡំ ការបង្ហាញឆន្ទៈពុំមានសុពលភាពទេ។ ក៏ប៉ុន្តែ បើសិនជាអ្នកបង្ហាញឆន្ទៈមានកំហុសធ្ងនធ្ងរ អ្នកនោះមិនអាចអះអាងអំពីអសុពលភាពនេះដោយខ្លួនឯងបានទេ។

នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ពុំមានបញ្ញត្តិចែងបែបនេះទេ។ បើសិនជាXអះអាងដូចខាងក្រោមនេះ តើត្រូវគិតយ៉ាងណាដែរ ?

ឧទាហរណ៍ : Yគឺជាអ្នករកស៊ីលក់ដូរវត្ថុបុរាណ ដូច្នេះ គាត់អាចដឹងយ៉ាងងាយស្រួល អំពីវត្ថុក្លែងក្លាយ។

23

## 3 សង្ខេបអំពីការតវ៉ាស្ដីពីការភាន់ច្រឡំ (ការរៀបចំការអះអាង)

1 មូលហេតុនៃការទាមទារ

(1) នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៤ ដើមចោទបានលក់ថូ P ក្នុងតម្លៃ១ម៉ឺនដុល្លារចំពោះចុងចម្លើយ។

(2) ហេតុនេះហើយ ដើមចោទទាមទារឱ្យចុងចម្លើយបង់ថ្លៃ១ម៉ឺនដុល្លារ ដោយផ្អែកលើកិច្ចសន្យាលក់ទិញនេះ។

2 ការទទួលស្គាល់ឬមិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ

ទទួលស្គាល់នូវមូលហេតុនៃការទាមទារ (1)។

3 ការតវ៉ា

ចុងចម្លើយបានទទួលការពន្យល់ពីដើមចោទថា ថូបុរាណ P នោះ គឺជាស្នាដៃរបស់សិល្បករល្បីម្នាក់ ហើយក៏បានបង្ហាញឆន្ទៈទិញ ដោយសារជឿការពន្យល់នោះ។ ក៏ប៉ុន្តែ ថូ P នោះ គឺជាវត្ថុក្លែងក្លាយ។

4 ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះការតវ៉ា

មិនទទួលស្គាល់ការតវ៉ា។

24

# 3 ការតវ៉ាស្តីពីការភាន់ច្រឡំ

មូលហេតុនៃការទាមទារ ការតវ៉ា




25

# 4 ការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ

26

## 4 អង្គហេតុចំបងនៃការតវ៉ាស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ(1)

សូមពិចារណាអំពីអង្គហេតុចំបងដែលជាធាតុផ្សំនៃ “ការតវ៉ាស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ” ដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណី

### (1) មានស្ថានភាពអាចអនុវត្តសិទ្ធិបាន

CC មាត្រា481 (ការចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល)

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន ។

លើសពីនេះ ការអាចអនុវត្តសិទ្ធិ គឺមានឡើងនៅក្នុងការអះអាងរបស់ X (ex : ថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩, កិច្ចសន្យាលក់ទិញរវាង X និងY)
ដូច្នេះ Yមិនចាំបាច់អះអាងនិងបញ្ជាក់ភស្តុតាងជាថ្មីអំពី (1) ទេ។

27

## 4 អង្គហេតុចំបងនៃការតវ៉ាស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ(2)

### (2) អំឡុងពេល៥ឆ្នាំបានកន្លងផុតពីពេលនៃ (1)

CC មាត្រា482 (អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលំត់សិទ្ធិលើបំណុលទូទៅ)

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង ។

### (3) អ្នកមានសិទ្ធិលើកឡើង បានបង្ហាញឆន្ទៈលើកឡើងនូវអាជ្ញាយុកាលចំពោះភាគីម្ខាងទៀត

CC មាត្រា486 កថាខ័ណ្ឌទី1 (ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល)

តុលាការមិនអាចសម្រេចសេចក្តីដោយយកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានឡើយ លើកលែងតែភាគីបានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ ។

28

## 4 អង្គហេតុចំបងនៃការតវ៉ាស្ដីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ(3)

### លទ្ធផល

អង្គហេតុចំបងដែលជាល័ក្ខខ័ណ្ឌនៃ(2) និង(3) ហើយដែល Y ត្រូវអះអាងជាការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ គឺ

1 ថ្ងៃទី៣ ខែមីនា ឆ្នាំ ២០១៩ បានកន្លងផុតទៅ។

2 ចុងចម្លើយបានលើកឡើងនូវអាជ្ញាយុកាលខាងលើនេះ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ ចំពោះដើមចោទ។



## 4 （ឯកសារយោង） ការតវ៉ាតបរបស់ X

CC មាត្រា 489 (ហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល)

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវផ្អាកក្នុងករណីដូចតទៅ ៖

ក-ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីធនក្ស័យ ឬ ការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល ។

ខ- (រំលង)

គ-ការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬ វិធីផ្សេង ។

## 4 សង្ខេបអំពីការតវ៉ាស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ (ការរៀបចំនូវការអះអាង)

1 មូលហេតុនៃការទាមទារ
(1) នៅថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៩ ដើមចោទបានលក់ថូ P ក្នុងតម្លៃ១ម៉ឺនដុល្លារ ចំពោះចុងចម្លើយ។
(2) ហេតុនេះហើយ ដើមចោទទាមទារចំពោះចុងចម្លើយ ឱ្យបង់ថ្លៃ១ម៉ឺនដុល្លារ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ។
2 ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ
មិនទទួលស្គាល់នូវមូលហេតុនៃការទាមទារ (1)។
3 ការតវ៉ា
(1) ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៤ បានកន្លងផុត។
(2) នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ចុងចម្លើយបានលើកឡើងនូវអាជ្ញាយុកាលខាងលើនេះ ចំពោះដើមចោទ។
4 ការតវ៉ាតប
នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ចុងចម្លើយបានបង់ប្រាក់១000ដុល្លារ ដែលជាមួយភាគនៃថ្លៃថូ P ចំពោះដើមចោទ។
5 ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះការតវ៉ាតប
មិនទទួលស្គាល់។

31

## 4 ការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ




32

# 5 ល័ក្ខខ័ណ្ឌ-អំឡុងពេល

(ការតវ៉ាអំពីល័ក្ខខ័ណ្ឌបង្អង់, ការតវ៉ាអំពីអំឡុងពេលអនុវត្ត)

33

# 5 – 1 ការតវ៉ាអំពីល័ក្ខខ័ណ្ឌបង្អង់

CC មាត្រា325 កថាខ័ណ្ឌទី3 (អត្ថន័យនៃល័ក្ខខ័ណ្ឌ)

ក្នុងករណីដែលដាក់ល័ក្ខខ័ណ្ឌបង្អង់លើកាតព្វកិច្ច ឬ សិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី អានុភាពនៃកាតព្វកិច្ច ឬ សិទ្ធិនោះ ត្រូវកើតឡើងចាប់តាំងពីពេលដែលល័ក្ខខ័ណ្ឌបង្អង់នោះត្រូវបានបំពេញ ។

34

## 5－2　ការតវ៉ាអំពីអំឡុងពេលអនុវត្ត

CC មាត្រា329 កថាខ័ណ្ឌទី1 (អត្ថន័យនៃការកំណត់ពេល)

ក្នុងករណីដែលមានកំណត់ពេលចាប់ផ្តើម ចំពោះអានុភាពនៃកិច្ចសន្យា អានុភាពនោះមិនត្រូវកើតឡើង រហូតដល់ពេលកំណត់នោះមកដល់ ។ ក្នុងករណីដែលមានកំណត់ពេលចាប់ផ្តើម ចំពោះការអនុវត្តកិច្ចសន្យា ម្ចាស់បំណុលមិនអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច មុនពេលកំណត់នោះបានឡើយ ។

35

## 5　សង្ខេបអំពីល័ក្ខខ័ណ្ឌ អំឡុងពេល (ការរៀបចំការអះអាង)

1　មូលហេតុនៃការទាមទារ

(1)　នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤ ដើមចោទបានលក់ថូ P ក្នុងតម្លៃ ១ម៉ឺនដុល្លារ ចំពោះចុងចម្លើយ (ខាងក្រោមនេះ ហៅកាត់ថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ")។

(2)　ហេតុនេះហើយ ដើមចោទទាមទារឱ្យចុងចម្លើយបង់ថ្លៃ១ម៉ឺនដុល្លារ ដោយផ្អែកលើកិច្ចសន្យាលក់ទិញនេះ។

2　ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ

ទទួលស្គាល់នូវមូលហេតុនៃការទាមទារ (1)។

3　ការតវ៉ា

នៅពេលបង្កើតកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ ដើមចោទ និង ចុងចម្លើយ បានព្រមព្រៀងអំពីពេលបង់ថ្លៃជាប្រាក់ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤។

4　ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះការតវ៉ា

មិនទទួលស្គាល់នូវការតវ៉ា។

36

## 5 ល័ក្ខខ័ណ្ឌ-អំឡុងពេល

(ការតវ៉ាអំពីល័ក្ខខ័ណ្ឌបង្អង់, ការតវ៉ាអំពីអំឡុងពេលអនុវត្ត)




37

# 6 ការតវ៉ាឱ្យអនុវត្តព្រមគ្នា

38

# 6 ការតវ៉ាឱ្យអនុវត្តព្រមគ្នា

CC មាត្រា558 កថាខ័ណ្ឌទី1 (សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា)

អ្នកទិញអាចមិនព្រមបង់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់បានផ្តល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកលក់មិនទាន់ដល់ពេលកំណត់ត្រូវសង ឬករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តកាតព្វកិច្ចបង់ថ្លៃជាមុន ។

【ឯកសារយោង】 សំណើផ្តល់ការសង (CC មាត្រា453 កថាខ័ណ្ឌទី1)

សំណើផ្តល់ការសង សំដៅទៅលើការដែលកូនបំណុលបានរៀបចំចប់សព្វគ្រប់ នូវតារកាលិកសម្រាប់សង និង ទាមទារឱ្យម្ចាស់បំណុលទទួលការសងនោះ ។

39

# 6 សង្ខេបអំពីការតវ៉ាឱ្យអនុវត្តព្រមគ្នា

## (ការរៀបចំនូវការអះអាង)

1 មូលហេតុនៃការទាមទារ

(1) នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤ ដើមចោទបានលក់ថូ P ក្នុងតម្លៃ ១ម៉ឺនដុល្លារ ចំពោះចុងចម្លើយ (ខាងក្រោមនេះ ហៅកាត់ថា “កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ”)។

(2) ហេតុនេះហើយ  ដើមចោទទាមទារឱ្យចុងចម្លើយបង់ថ្លៃ១ម៉ឺនដុល្លារ ដោយផ្អែកលើកិច្ចសន្យាលក់ទិញនេះ។

2 ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ

ទទួលស្គាល់នូវមូលហេតុនៃការទាមទារ (1)។

3 ការតវ៉ា

ចុងចម្លើយប្រកែកមិនបង់ថ្លៃលក់ទិញ រហូតដល់ពេលដើមចោទប្រគល់ថូ P នោះ (ការអះអាងអំពីសិទ្ធិ)។

4 ការតវ៉ាតប

រវាងដើមចោទ និង ចុងចម្លើយ មានការព្រមព្រៀងអំពីការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបង់ថ្លៃលក់ទិញជាមុន។

5 ការទទួលស្គាល់ឬមិនទទួលស្គាល់ចំពោះការតវ៉ាតប

មិនទទួលស្គាល់ការតវ៉ាតប។

40

# 6 ការតវ៉ាឱ្យអនុវត្តព្រមគ្នា




41

# 7 ការតវ៉ាអំពីការសង

42

# 7　ការតវ៉ាអំពីការសង

CC មាត្រា384 (ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច)

១-កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

២-ការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាការសង ដែលនាំឱ្យកាតព្វកិច្ចរលត់ ។

CC មាត្រា433 (មូលហេតុនៃការរលត់កាតព្វកិច្ច)

កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ ៖

ក-ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ព្យាកុលភាព ដូចបានកំណត់ ពីផ្នែកទី ១ (ការសង) ដល់ផ្នែកទី ៥ (ព្យាកុលភាព) នៃជំពូកទី ៧ នេះ ។

43

# 7　សង្ខេបអំពីការតវ៉ាអំពីការសង
## (ការរៀបចំនូវការអះអាង)

1　មូលហេតុនៃការទាមទារ

(1)　នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤ ដើមចោទបានលក់ថូ P ក្នុងតម្លៃ ១ម៉ឺនដុល្លារ ចំពោះចុងចម្លើយ (ខាងក្រោមនេះ ហៅកាត់ថា “កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ”)។

(2)　ហេតុនេះហើយ ដើមចោទទាមទារឱ្យចុងចម្លើយបង់ថ្លៃ១ម៉ឺនដុល្លារ ដោយផ្អែកលើកិច្ចសន្យាលក់ទិញនេះ។

2　ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ

ទទួលស្គាល់នូវមូលហេតុនៃការទាមទារ (1)។

3　ការតវ៉ា

ចុងចម្លើយបានបង់ប្រាក់១ម៉ឺនដុល្លារដែលជាការអនុវត្តកាតព្វកិច្ចបង់ថ្លៃនៃរឿងក្តីនេះ។

4　ការទទួលស្គាល់ឬមិនទទួលស្គាល់ចំពោះការតវ៉ា

មិនទទួលស្គាល់ការតវ៉ា។

44

# 7 ការតវ៉ាអំពីការសង

មូលហេតុនៃការទាមទារ

ការតវ៉ា

X・Y កិច្ចសន្យាលក់ទិញ

ការសង

①ការផ្តល់តារកាលិកតាមគោលគំនិតនៃកាតព្វកិច្ច

②ទំនាក់ទំនងរវាងតារកាលិកនិងសិទ្ធិលើបំណុល

45

# 8 សង្ខេប

46

# 8 សង្ខេប

- អង្គហេតុចំបងដែលជាធាតុផ្សំ
  គឺជាការវិភាគអំពីបញ្ញត្តិនៃច្បាប់សារធាតុ (ក្រមរដ្ឋប្បវេណី) ដោយមើលពីទស្សនៈស្ដីពីការតទល់និងការពារខ្លួន (តើភាគីណាមួយជាអ្នកទទួលបន្ទុកក្នុងការអះអាងនិងបញ្ជាក់ភស្តុតាង)
- តួនាទីរបស់តុលាការ
  - ✓ រៀបចំនូវចំណុចវិវាទ (តើអង្គហេតុអ្វីខ្លះដែលត្រូវបញ្ជាក់ភស្តុតាង?) ដោយពិចារណាអំពីល័ក្ខខ័ណ្ឌចាំបាច់គ្រប់គ្រាន់ដើម្បីធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃការទាមទាររបស់ដើមចោទ (កម្មវត្ថុនៃបណ្ដឹង)
- តួនាទីរបស់អ្នកតំណាង (មេធាវី)
  - ✓ ស្ដីពីអង្គហេតុដែលខ្លួនមានការទទួលខុសត្រូវក្នុងការអះអាងនិងបញ្ជាក់ភស្តុតាង (ex. បើសិនជាដើមចោទ គឺមូលហេតុនៃការទាមទារ) ត្រូវពិចារណាមើលថា តើអាចបញ្ជាក់នូវមូលហេតុនៃការទាមទារដោយភស្តុតាងគ្រប់គ្រាន់ដែរឬទេ (ទោះជាចុងចម្លើយមិនទទួលស្គាល់នូវមូលហេតុនៃការទាមទារទាំងអស់ក៏ដោយ)
  - ✓ ក្នុងករណីដែលអាចស្មានដឹងថា មានការតវ៉ាពីចុងចម្លើយ ត្រូវពិចារណាថាតើអាចបញ្ជាក់ភស្តុតាងនៃអង្គហេតុដែលជាមូលដ្ឋាននៃការតវ៉ាតប ឬទេ។

47

# សូមអរគុណ !

48